## មាតិកានៃរិបសែ

## មាតិកានៃរិបសែ - កំណែចុងក្រោយ

សេវាអំពើហិង្សាក្នុងផ្ទះសំរាប់ស្ត្រីអន្តោប្រវេសន៍ (IWDVS) គឺជាសេវា(កិច្ចបំរើ)ទូទាំងរដ្ឋ ដែលផ្តល់ជំនួយនិងអន្តរាគមន៍ពេលមានវិបត្តិជូនចំពោះស្ត្រីនិងកុមារមកពីសាវតារវប្បធម៌និងភាសាផ្សេងៗគ្នា ដែលជួបប្រទះនឹងអំពើហិង្សាក្នុងផ្ទះ។ ពេលបច្ចុប្បន្ននេះ គេផ្តល់ជំនួយភាសាតាមរយៈភាសាដូចតទៅនេះ: វៀតណាម ចិនកុកងឺ ចិនកន្តាំង ទួរគី ដារី ពូស្តូ ហ្វាស៊ី គូដ ពែរក្ស៊ី អាំហារិក ទិគ្រី ស៊ូដង់ទីក្រិនយ៉ាន (អារ៉ាប់ ឌីនកា និង ណួរ ស្ទីលលុក) រុស្ស៊ី អ៊ុយក្រែន បែលរុស្ស៊ី ប៊ុលហ្គារី ក្រិក ស៊ែរប៊ី ម៉ាសេដូនី បូស្នី ក្រូអាទី ស្លូវេនី អេស្ប៉ាញ (សំរាប់ប្រទេសជាង 20 ដែលនិយាយភាសាអេស្ប៉ាញ) និងអារ៉ាប់ (សំរាប់ប្រទេសជាង 20 ដែលនិយាយភាសាអារ៉ាប់)។ យើងខ្ញុំធ្វើការជាមួយអ្នកបកប្រែភាសានៅពេលដែលយើងខ្ញុំពុំមានបុគ្គលិកករណីដែលនិយាយភាសារបស់អតិថិជន។

### ទស្សនៈវិស័យ

ទស្សនៈវិស័យរបស់ IWDVS គឺសំរាប់ឲ្យស្ត្រីនិងកុមារទាំងអស់គ្រប់គ្រងជីវិតរបស់ខ្លួនឯងផ្ទាល់ នៅក្នុងសង្គមមួយដែលគ្មានអំពើហិង្សា ដែលរួមទាំងការប្រកាន់រើសអើង។

### គោលបំណង

IWDVS ផ្តល់សម្លេងនិងផ្តល់សេវាដែលគិតគូរខ្លាំងនូវវប្បធម៌ នៅទូទាំងរដ្ឋ ដើម្បីបំពេញសេចក្តីត្រូវការរបស់ស្ត្រីនិងកុមារមកពីសាវតារវប្បធម៌និងភាសាផ្សេងៗគ្នា ដែលរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងផ្ទះ។

### តម្លៃ

យើងខ្ញុំជឿជាក់លើគោលការណ៍ស្ត្រីនិយមនិងសិទ្ធិមនុស្ស
យើងខ្ញុំផ្តល់អាទិភាពចំពោះសារសំខាន់នៃការសំរេចបាននូវសុវត្ថិភាព
យើងខ្ញុំគោរពភាពខុសៗគ្នានិងតម្លៃរៀងៗខ្លួនរបស់ស្ត្រីទាំងឡាយ
យើងខ្ញុំលើកកំពស់សិទ្ធិរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួនឯងផ្ទាល់
យើងខ្ញុំគោរពការលាក់ការសម្ងាត់ ការទុកចិត្ត និងសិទ្ធិនៃភាពផ្ទាល់ខ្លួន
យើងខ្ញុំលើកតំកើងវិជ្ជាជីវៈនិយមរបស់បុគ្គលិកនិងក្រុមប្រឹក្សារបស់យើងខ្ញុំ
យើងខ្ញុំទទួលស្គាល់សារសំខាន់នៃការធ្វើការងារដែលមានកិច្ចសហការ

### លក្ខណៈវិនិច្ឆ័យ

ស្ត្រីនិងកុមារជួបប្រទះ និង/ឬ រត់គេចចេញពីអំពើហិង្សាក្នុងផ្ទះ
ស្ត្រីនិងកុមារមកពីសាវតារវប្បធម៌និងភាសាផ្សេងៗគ្នា
ស្ត្រីនិងកុមាររស់នៅក្នុងរដ្ឋវិចតូរីយ៉ា

**តើអំពើហិង្សាក្នុងផ្ទះ គឺជាអ្វី?**

អំពើហិង្សាក្នុងផ្ទះនិងអំពើហិង្សាគ្រួសារមានច្រើនប្រភេទ។ ប្រភេទទាំងអស់នេះបណ្តាលឲ្យមានគ្រោះថ្នាក់។ តទៅនេះគឺជាឧទាហរណ៍ខ្លះនៃអំពើហិង្សាក្នុងគ្រួសារ:

**រាងកាយ:** វាយដំ ទាត់ធាក់ ទះកំភ្លៀង ច្របាច់ក គប់ដោយវត្ថុនានា បោចទាញសក់ ឬការវាយដំរាងកាយតាមទំរង់ផ្សេងៗទៀត។

**ផ្លូវភេទ:** ការចាប់អារម្មណ៍លើផ្លូវភេទដែលអ្នកគ្មានចេតនា បង្ខំឲ្យរួមភេទឬធ្វើអ្វីៗដែលទាក់ទងនឹងការរួមភេទដោយជំទាស់នឹងឆន្ទៈរបស់អ្នក។

**ផ្លូវចិត្ត:** គំរាមកំហែងយកកូនអ្នកចេញពីអ្នក បង្កការខូចខាតដល់ទ្រព្យសម្បត្តិ ធ្វើឲ្យអាម៉ាស់មុខ ឬគំរាមកំហែងយាយីរាងកាយឬគំរាមកំហែងសម្លាប់អ្នក កូនអ្នក ឬអ្នកផ្សេងទៀត។

**ពាក្យសម្តី:** ដាក់ងារមិនល្អ ជេរស្តី ឬបន្ទាបបន្ថោក។

**សង្គម:** មិនឲ្យអ្នកជួបគ្រួសារនិងមិត្តភក្តិរបស់អ្នក មិនអនុញ្ញាតឲ្យអ្នកចាកចេញពីផ្ទះ ឬខិតខំត្រួតត្រាទីកន្លែងដែលអ្នកធ្វើដំណើរទៅ ឬជនដែលអ្នកជួប។

**ប្រាក់កាស:** មិនឲ្យប្រាក់កាសអ្នកគ្រប់គ្រាន់ ដើម្បីបំពេញតាមសេចក្តីត្រូវការជាគោលការណ៍របស់អ្នកនិងកូនអ្នក ឧទាហរណ៍: លុយសំរាប់ទិញចំណីអាហារឬបង់ថ្លៃប័ណ្ណទារប្រាក់ផ្សេងៗ។

**តាមយាយី:** ធ្វើដំណើរទៅតាមអ្នកឬទាក់ទងអ្នកម្តងហើយម្តងទៀត ដោយមានបំណងបង្កគ្រោះថ្នាក់ដល់រូបអ្នក ឬធ្វើឲ្យអ្នកភិតភ័យ។

**ផ្លូវច្បាប់:** បុរសជាច្រើនដែលប្រើអំពើហិង្សា គំរាមកំហែងយកកូនចេញពីអ្នក ឬថា អ្នកនឹងបាត់បង់សិទ្ធិម្ចាស់កម្មសិទ្ធិផ្ទះរបស់គ្រួសារ ដើម្បីគ្រប់គ្រងអ្នក ឬបញ្ឈប់អ្នកមិនឲ្យចាកចេញពីខ្លួន។ នៅក្នុងប្រទេសអូស្ត្រាលី ឪពុកឬម្តាយមិនអាចឃាត់ឃាំងឪពុកឬម្តាយមួយទៀតមិនឲ្យជួបកូនបានឡើយ។ IWDVS អាចតភ្ជាប់អ្នកទៅកាន់មេធាវី ដើម្បីធ្វើឲ្យប្រាកដថា អ្នកអាចជួបនិងស្នាក់នៅជាមួយកូនអ្នក និងទទួលទ្រព្យសម្បត្តិរបស់គ្រួសារ។

**អន្តោប្រវេសន៍:** ជនប្រើអំពើហិង្សាច្រើននាក់ប្រើឋានៈអន្តោប្រវេសន៍របស់ដៃគូរួមមេត្រីរបស់ខ្លួន ជាវិធីមួយទៀតដើម្បីគ្រប់គ្រងអ្នកទាំងនោះ។ អំពើរំលោភអាចកើតមានតាមទំរង់ដូចតទៅនេះ:

- ដុតឬលួចយកឯកសាររបស់អ្នកឬឯកសាររបស់កូនអ្នក។
- បដិសេធមិនព្រមជួយអ្នកឲ្យទទួលឋានៈស្របច្បាប់។
- ដាក់ងារឲ្យអ្នកមិនល្អ ដូចជាហៅថា"ជនខុសច្បាប់"។
- គំរាមកំហែងថា នឹងប្រាប់ឲ្យគេបញ្ជូនអ្នកចេញពីប្រទេស
- រាយការណ៍អំពីអ្នកប្រាប់ទៅក្រសួងអន្តោប្រវេសន៍។

ជនរងគ្រោះជាច្រើននៃអំពើហិង្សាក្នុងផ្ទះ ភ័យខ្លាចក្នុងការរាយការណ៍ ឬចាកចេញពីជនដែលរំលោភវាយដំខ្លួនគេ ដោយសារតែខ្លួន"គ្មានឯកសារស្របច្បាប់"។ ទោះជាការគំរាមកំហែងនៃការបញ្ជូនឲ្យវិលទៅប្រទេសដើមវិញគឺជាការពិតប្រាកដក្តី ក៏សុវត្ថិភាពរបស់អ្នកមានសារសំខាន់បំផុត។

ពិគ្រោះយោបល់ជាមួយមេធាវីឬភ្នាក់ងារអន្តោប្រវេសន៍ចុះបញ្ជីត្រឹមត្រូវ ដើម្បីសុំឱវាទ។ IWDVS មានភ្នាក់ងារអន្តោប្រវេសន៍ ដែលអាចជួយអ្នកបាន។

សុវត្ថិភាពរបស់អ្នកគឺសំខាន់ណាស់។ អ្នកមានសិទ្ធិដើម្បីទទួលកិច្ចការពារ ទោះជាអ្នកពុំមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍ក៏ដោយ។

## ផលប៉ះពាល់នៃអំពើហិង្សាក្នុងផ្ទះ

អំពើហិង្សាក្នុងផ្ទះគឺជាអំពើឧក្រិដ្ឋកម្ម។ ការវាយដំរាងកាយឬរំលោភផ្លូវភេទលើអ្នកណាម្នាក់ ការគំរាមកំហែងដើម្បីវាយដំឬធ្វើឃាត ឬការវាយដំជនម្នាក់ទៀត គឺជាឧក្រិដ្ឋកម្មនៅក្នុងរដ្ឋវិចតូរីយ៉ា។ ប៉ូលិសអាចចាប់ខ្លួន និងប្តឹងចោទជនដែលវាយដំរាងកាយរបស់សមាជិកគ្រួសារ។

អំពើហិង្សាក្នុងគ្រួសារបណ្តាលឲ្យមានគ្រោះថ្នាក់។ ការរងនូវអំពើហិង្សាក្នុងផ្ទះ បណ្តាលឲ្យមានផលលំបាកផ្លូវចិត្តនិងរាងកាយយ៉ាងធ្ងន់ធ្ងរចំពោះជនរងគ្រោះ ជនរងគ្រោះដែលគ្មានចេតនាទៅលើ ដូចជាកុមារ និងជនដែលប្រើអំពើហិង្សា។

## អំពើហិង្សាបំផ្លាញចំណងមេត្រីភាព

អំពើហិង្សាបំផ្លាញចំណងមេត្រីភាព។ អំពើហិង្សាបណ្តាលឲ្យសមាជិកគ្រួសារខ្លាចគ្នាទៅវិញទៅមក។ ហេតុការណ៍នេះនឹងបំផ្លិចបំផ្លាញសេចក្តីស្រឡាញ់ និងសេចក្តីទុកចិត្ត ដែលជាស្នូលកណ្តាលចំពោះសុខុមាលភាពគ្រួសារ។

ជាញឹកញយ គេដាក់កំហុសលើសេវាជំនួយប្រឆាំងនឹងអំពើហិង្សាក្នុងផ្ទះ ចំពោះការជួយស្ត្រីនិងកុមារឲ្យមានសុវត្ថិភាព។ សហគមន៍ទាំងឡាយនិយាយថា ជំនួយនេះធ្វើឲ្យគ្រួសារបែកបាក់គ្នា។ តាមពិតទៅចំណងចងភ្ជាប់របស់គ្រួសារ បានបែកបាក់រួចទៅហើយដោយសារតែអំពើហិង្សានេះ។ អំពើហិង្សាបំបែកបំបាក់គ្រួសារ។

## អ្នកមានសិទ្ធិស្វែងរកសុវត្ថិភាពនិងជំនួយ

អ្នកមិននៅតែឯងទេ។ មនុស្សក្នុងគ្រួសារនិងសហគមន៍របស់អ្នកអាចបំបាក់ទឹកចិត្តអ្នកកុំឲ្យស្វែងរកជំនួយ។ អ្នកទាំងនោះអាចដាក់សម្ពាធលើអ្នកកុំឲ្យចាកចេញពីដៃគូរួមមេត្រីរបស់អ្នកដែលប្រើអំពើហិង្សា។ យ៉ាងណាមិញ អ្នកមិនមែនជាជនប្រើអំពើហិង្សាឡើយ។ អ្នកមានសិទ្ធិស្វែងរកជំនួយនិងកិច្ចការពារ។ នេះមិនមែនមានន័យថាអ្នកនឹងបែកបាក់គ្នានោះទេ។ ទង្វើនេះអាចធ្វើឲ្យដៃគូរួមមេត្រីរបស់អ្នកដឹងថា អ្នកមិននៅតែឯងទៀតឡើយ។ សេវាជំនួយប្រឆាំងនឹងអំពើហិង្សាក្នុងផ្ទះដូចជា IWDVS អាចជួយអ្នកក្នុងការការពារខ្លួនអ្នកនិងកូនអ្នក។

នៅពេលដែលយើងខ្ញុំធ្វើការជាមួយអ្នក យើងខ្ញុំពន្យល់លក្ខណៈចរិតនៃអំពើហិង្សាក្នុងផ្ទះ ពន្យល់អំពីតួនាទីនៃប្រព័ន្ធយុត្តិធម៌ ប្រាប់អំពីសិទ្ធិនិងជំរើសរបស់អ្នក និងផ្តល់ទីកន្លែងជំនួយក្នុងសហគមន៍ដែលអ្នកអាចទៅសុំជំនួយ។ យើងខ្ញុំសង្ឃឹមថា ព័ត៌មាននេះគឺជាផ្នែកចាប់ផ្តើមនៃអនាគតមានសុវត្ថិភាពមួយសំរាប់អ្នកនិងកូនអ្នក។

## របៀបដែលយើងខ្ញុំធ្វើការ

### ការគ្រប់គ្រងករណីរួមគ្នា

ក្នុងភាពជាសេវាមួយដែលបំរើការទូទាំងរដ្ឋ IWDVS ឆ្លើយតបនឹងសំណូមពរឲ្យមានសេវាសំរាប់គ្រប់កន្លែងទាំងអស់នៅក្នុងរដ្ឋវិចតូរីយ៉ា។ គោលបំណងរបស់យើងខ្ញុំគឺដើម្បីផ្តល់ជំនួយនិងជួយទ្រទ្រង់ផ្នែកវប្បធម៌សំរាប់ស្ត្រីនិងកុមារមកពីសាវតារវប្បធម៌ផ្សេងៗគ្នា។ ការគ្រប់គ្រងករណីមានទំនាក់ទំនងពិសេសនៅក្នុងការផ្តល់ជំនួយទៅកាន់អតិថិជនដែលមានសេចក្តីត្រូវការផ្សេងៗគ្នាដ៏ស្មុគស្មាញ ហើយដែលត្រូវការទទួលសេវាផ្សេងៗគ្នាយ៉ាងទូលំទូលាយ និងជំនួយតាមប្រភេទខុសៗគ្នា។ អតិថិជនភាគច្រើនត្រូវការនិងប្រើសេវាផ្សេងៗគ្នាយ៉ាងទូលំទូលាយ ដោយមានរួមទាំងទីលំនៅ ប្រាក់ចំណូល សុខភាព ការងារ ការសិក្សាអប់រំ និងការបណ្តុះបណ្តាល។ សេវា SAAP ខ្លះ ដូចជាសេវាបញ្ជូន ឬសេវាប្រមូលនិងចែកចាយព័ត៌មាន អាចចាប់ផ្តើមដំណើរការគ្រប់គ្រងករណី ដោយធ្វើការពិនិត្យវាយតម្លៃលំអិតមួយដើម្បីសំរេចលើការបញ្ជូនសមហេតុផលបំផុត។ បន្ទាប់មក ការគ្រប់គ្រងករណីត្រូវបានធ្វើបន្តដោយសេវាដែលគេបញ្ជូនអតិថិជនឲ្យទៅជួប។ IWDV ធ្វើការពិនិត្យវាយតម្លៃជាមួយនឹងអតិថិជន បន្ទាប់មកបញ្ជូនព័ត៌មានអំពីសេចក្តីត្រូវការផ្នែកវប្បធម៌ និងការជួយទ្រទ្រង់របស់អតិថិជនទៅកាន់ដៃគូផ្តល់សេវា។ បន្ទាប់មក គេធ្វើផែនការករណីក្នុងភាពជាដៃគូ។

IWDVS ធ្វើការព្រមគ្នានឹងសេវាផ្តល់ជំរកស្នាក់អាស្រ័យនិងពាក់ព័ន្ធនឹងអំពើហិង្សាក្នុងផ្ទះ ក្នុងការផ្តល់ជំនួយសំរាប់ស្ត្រីដែលជួបប្រទះនឹងអំពើហិង្សាក្នុងផ្ទះ។ ការបញ្ជូនអាចកើតចេញពីប្រភពដូចតទៅនេះ:

- ជំរកស្នាក់អាស្រ័យ: បុគ្គលិកជំរកស្នាក់អាស្រ័យពិនិត្យវាយតម្លៃសេចក្តីត្រូវការជំនួយផ្នែកវប្បធម៌និងភាសាជាក់លាក់; ឬស្ត្រីនៅក្នុងជំរកសុំឲ្យមានការជាប់ទាក់ទងជាក់លាក់ពី IWDVS ។
- សេវាឈានទៅដល់សហគមន៍ (Outreach services): បុគ្គលិកឈានទៅដល់សហគមន៍ពិនិត្យវាយតម្លៃសេចក្តីត្រូវការជំនួយផ្នែកវប្បធម៌និងភាសាជាក់លាក់សំរាប់អតិថិជន; ឬអតិថិជននៅក្នុងសេវាឈានទៅដល់សហគមន៍ សុំឲ្យមានការជាប់ទាក់ទងជាក់លាក់ពី IWDVS ។
- សេវាដទៃទៀត: នៅពេលមានការពិនិត្យវាយតម្លៃថា ស្ត្រីណាមួយមានសិទ្ធិទទួលសេវា IWDVS ហើយនោះ បុគ្គលិកអាចបញ្ជូនករណីនេះទៅកាន់ IWDVS ។
- ការបញ្ជូនដោយផ្ទាល់: គេទទួលទូរស័ព្ទពីស្ត្រីមានវិបត្តិ តាមរយៈទូរស័ព្ទសាធារណៈ។ ការពិនិត្យវាយតម្លៃវិបត្តិគឺដើម្បីធ្វើឲ្យដឹងច្បាស់អំពីជំហានបន្ទាប់ដែលស្ត្រីនោះមានបំណងចាប់យក។ គេអាចបញ្ជូនស្ត្រីនោះទៅកាន់ជំរកស្នាក់អាស្រ័យតាមរយៈ WDVCS ឬទៅកាន់សេវាឈានទៅដល់សហគមន៍។ ទោះជានៅក្នុងករណីណាក៏ដោយ ក៏ IWDVS នឹងធ្វើការជាមួយសេវាពាក់ព័ន្ធផ្សេងៗទៀត ដើម្បីផ្តល់ការគ្រប់គ្រងករណីរួមគ្នាសំរាប់ស្ត្រីនោះ។

## របៀបដែលសេវាយើងខ្ញុំអាចជួយអ្នក

វាអាចលំបាកក្នុងការដឹងនូវអ្វីៗដែលត្រូវធ្វើ បើអ្នកកំពុងជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសារ។ បុគ្គលិកជំនួយយើងខ្ញុំផ្តល់ជំនួយដោយផ្ទាល់មុខឬតាមទូរស័ព្ទ ទៅឲ្យស្ត្រីនិងកុមារដែលមានសាវតារវប្បធម៌និងភាសាផ្សេងៗគ្នា ហើយដែលជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសារ។

ដោយជួយអ្នក គោលបំណងចំបងរបស់បុគ្គលិកជំនួយគឺដើម្បីជួយអ្នកក្នុងការគ្រប់គ្រងថែមទៀតលើជីវិតរបស់អ្នក។ វិធីមួយគឺដោយផ្តល់ឲ្យអ្នកនូវព័ត៌មាននិងជំនួយដែលអាចជួយអ្នកក្នុងការសំរេចនូវអ្វីៗដែលត្រូវធ្វើសំរាប់ខ្លួនអ្នកផ្ទាល់។ វិធីតទៅនេះគឺជាវិធីខ្លះដែលបុគ្គលិកនោះអាចជួយអ្នក:

**ជំនួយផ្លូវចិត្ត និងព័ត៌មាន:** មិត្តភក្តិនិងគ្រួសារអាចជាជំនួយដ៏សំខាន់ណាស់។ វាពិតជាអាចមានប្រយោជន៍ក្នុងការនិយាយទៅកាន់អ្នកណាម្នាក់ដូចជាបុគ្គលិកជំនួយផ្នែកវប្បធម៌របស់អ្នកជាដើម ដែលមានការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ជំនួយផ្លូវចិត្តនិងព័ត៌មានទៅឲ្យអ្នក ហើយដើម្បីជួយអ្នកក្នុងការគិតអំពីជំរើសទាំងឡាយរបស់អ្នក។

**ធ្វើផែនការសុវត្ថិភាពមួយ:** បុគ្គលិកជំនួយផ្នែកវប្បធម៌អាចជួយអ្នកក្នុងការសំរេចលើជំហាននានាដែលអ្នកត្រូវការ ដើម្បីធ្វើឲ្យអ្នកនិងកូនអ្នកមានសុវត្ថិភាពនៅគ្រាឥឡូវនេះ និងដើម្បីធ្វើផែនការសុវត្ថិភាពរបស់អ្នកនៅថ្ងៃមុខ។

**ការពារកូនអ្នក:** កូនអ្នកមានសិទ្ធិទទួលនូវសុវត្ថិភាព។ បុគ្គលិកជំនួយផ្នែកវប្បធម៌នឹងធ្វើការជាមួយអ្នកលើបញ្ហានេះ ហើយឲ្យមានការចូលរួមពីសំណាក់សេវាផ្សេងទៀត តែនៅក្នុងករណីដែលបុគ្គលិកនេះបារម្ភថាខ្លួនអ្នកឬកូនអ្នកអាចមានគ្រោះថ្នាក់។

**ជំនួយពេលមានវិបត្តិ:** បើអ្នកមានអារម្មណ៍ថា ការផ្លាស់ប្តូរគឺជាការចាំបាច់ ឧទាហរណ៍ដូចជាការចាកចេញពីផ្ទះគ្រួសារនោះ បុគ្គលិកជំនួយផ្នែកវប្បធម៌អាចផ្តល់ឲ្យអ្នកនូវជំនួយផ្លូវចិត្ត និងជំនួយមានប្រយោជន៍ដូចជាការស្វែងរកទីកន្លែងសុវត្ថិភាពសំរាប់ស្នាក់នៅ ការទទួលជំនួយសំរាប់កូនអ្នក ការទទួលប្រាក់ជំនួយនិងការទទួលការពិគ្រោះយោបល់និងការគាំទ្រ។

**ជំនួយផ្លូវច្បាប់ / តុលាការ:** បុគ្គលិកជំនួយផ្នែកវប្បធម៌អាចប្រាប់អ្នកអំពីជំរើសផ្លូវច្បាប់ទាំងឡាយរបស់អ្នក។ ឧទាហរណ៍: ស្ត្រីជាច្រើនមិនដឹងថា អំពើហិង្សាគ្រួសារគឺជាអំពើឧក្រិដ្ឋទេ ហើយមិនដឹងថាខ្លួនអាចរាយការណ៍អំពីអំពើនេះទៅកាន់ប៉ូលិសនោះទេ។ ស្ត្រីជាច្រើនក៏មិនដឹងថា ខ្លួនពុំចាំបាច់ចាកចេញពីផ្ទះរបស់ខ្លួនឡើយ បើខ្លួនកំពុងជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសារនោះ។ ផ្ទុយទៅវិញ ស្ត្រីអាចទទួលបញ្ជាអន្តរាគមន៍ (intervention order) ប្រឆាំងនឹងជនដែលធ្វើបាបដល់ស្ត្រីនោះ។ នេះគឺជាបញ្ជាមួយរបស់តុលាការ ដែលតម្រូវឲ្យជននោះចាកចេញពីផ្ទះគ្រួសារ និងមិនឲ្យទៅក្បែរជនរងគ្រោះដែលខ្លួនបានប្រព្រឹត្តអំពើហិង្សាទៅលើនោះឡើយ។ បុគ្គលិកជំនួយផ្នែកវប្បធម៌អាចផ្តល់ជំនួយឲ្យអ្នកក្នុងការនិយាយទៅកាន់ប៉ូលិស ឡើងទៅតុលាការ ឬដាក់ពាក្យសុំបញ្ជាអន្តរាគមន៍។

**ព័ត៌មាននិងការបញ្ជូន:** បុគ្គលិកជំនួយផ្នែកវប្បធម៌អាចបញ្ជូនអ្នកទៅកាន់សេវាច្រើនផ្សេងៗទៀត ដែលអាចជួយអ្នកនិងកូនអ្នក។ សេវាទាំងនេះរួមមានមណ្ឌលប្រឆាំងនឹងការរំលោភផ្លូវភេទ សេវារបស់កុមារ ការពិគ្រោះឱវាទដោយឥតគិតថ្លៃឬតម្លៃថោក ជំរកស្នាក់អាស្រ័យ សេវាទីលំនៅ អ្នកពិគ្រោះឱវាទខាងប្រាក់កាស និងសេវាសំរាប់បុរសដែលប្រើអំពើហិង្សា និងមានបំណងផ្លាស់ប្តូរឥរិយាបថរបស់ខ្លួន។

**អន្តោប្រវេសន៍:** IWDVS មានភ្នាក់ងារអន្តោប្រវេសន៍ម្នាក់ដែលមានឯកទេសផ្នែក"ខ"អំពើហិង្សាក្នុងផ្ទះនៃច្បាប់អន្តោប្រវេសន៍។ គេមានឱវាទនិងជំនួយមានកំរិតកំណត់ខាងផ្នែកអន្តោប្រវេសន៍អំពី"ខ"អំពើហិង្សាក្នុងផ្ទះ។

## អ្វីៗដែលអ្នករំពឹងទទួលបានពីសេវានេះ

សេវាអំពើហិង្សាក្នុងផ្ទះសំរាប់ស្ត្រីអន្តោប្រវេសន៍ (IWDVS) មានបុគ្គលិកមួយក្រុមដែលបានទទួលការបណ្តុះបណ្តាលដើម្បីដោះស្រាយគ្រប់ចំណុចទាំងអស់នៃអំពើហិង្សាក្នុងផ្ទះនិងក្នុងគ្រួសារ។ ការងារទាំងអស់របស់យើងខ្ញុំ ត្រូវបានផ្អែកលើការទទួលស្គាល់សិទ្ធិមនុស្សជាគោលការណ៍របស់ស្ត្រីនិងកុមារ ដែលអាចជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសារ។

យើងខ្ញុំជឿថា អ្នកមានសិទ្ធិដើម្បី:

- រស់នៅដោយគ្មានអំពើហិង្សា និងការភ័យខ្លាច
- ទទួលការប្រព្រឹត្តិអំពើមកលើដែលប្រកបដោយសេចក្តីថ្លៃថ្នូរនិងការគោរព
- ទទួលជំនួយដោយគ្មានការវិនិច្ឆ័យ
- រក្សាការសម្ងាត់និងភាពផ្ទាល់ខ្លួន (ដោយផ្អែកលើគ្រោះថ្នាក់ចំពោះអ្នកនិងកូនអ្នក)
- ទទួលព័ត៌មានពាក់ព័ន្ធ ដែលនឹងអាចឲ្យអ្នកធ្វើសេចក្តីសំរេចចិត្តដោយជ្រាបដឹងព័ត៌មាន
- ធ្វើសេចក្តីសំរេចចិត្តដោយខ្លួនអ្នកផ្ទាល់ អំពីការរស់នៅរបស់អ្នក និងកូនអ្នក
- ទទួលជំនួយក្នុងដំណោះស្រាយជាមួយប៉ូលិស តុលាការ និងសេវាឯទៀត

សេវាអំពើហិង្សាក្នុងផ្ទះសំរាប់ស្ត្រីអន្តោប្រវេសន៍ គឺជាសេវាដែលផ្តោតលើស្ត្រី។ អាទិភាពចំបងរបស់យើងខ្ញុំ គឺដើម្បីគាំទ្រនិងជួយអ្នកឲ្យមានការគ្រប់គ្រងថែមទៀតលើជីវិតអ្នក។ ការនិយាយទៅកាន់បុគ្គលិកយើងខ្ញុំគឺជាការមានប្រយោជន៍ នៅពេលដែលអ្នកទាក់ទងជាដំបូងអំពីអ្វីៗដែលអ្នកអាចរំពឹងទទួលពីសេវាយើងខ្ញុំ។

## ការធ្វើផែនការសុវត្ថិភាព

ឧទាហរណ៍ខ្លះនៃផែនការសុវត្ថិភាពមានរួមទាំងការ:

- ធ្វើដំណើរទៅកាន់ជំរកស្នាក់អាស្រ័យរបស់ស្ត្រី
- ទៅតុលាការដើម្បីដាក់ពាក្យសុំកិច្ចការពារ
- រកមេដឹកនាំសហគមន៍ឬសាសនា ដើម្បីនិយាយទៅកាន់ជនប្រព្រឹត្តអំពើហិង្សា

- រកការពិគ្រោះឱវាទសំរាប់ប្តីរបស់អ្នក
- ទទួលការពិគ្រោះឱវាទសំរាប់គ្រួសារ
- ហៅប៉ូលិសដើម្បីឲ្យជួយការពារ
- បង្ហាត់កូននូវរបៀបស្វែងរកជំនួយក្នុងអម្លុងឧប្បត្តិហេតុនៃអំពើហិង្សា
- ទៅកាន់ការពិគ្រោះឱវាទដោយខ្លួនឯង ដើម្បីស្ថាបនាទំនុកចិត្តលើខ្លួនឯង និងកម្លាំងរបស់អ្នក
- ចូលរួមក្រុមជំនួយជាមួយនឹងស្ត្រីឯទៀត ដែលបានទទួលរងនូវអំពើហិង្សាក្នុងផ្ទះ។

ទូរស័ព្ទទៅកាន់ IWDVS តាមលេខ 9898 3145 ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 9:30 ព្រឹកដល់ម៉ោង 5:15 ល្ងាច ដើម្បីទទួលព័ត៌មានអំពីអ្វីៗដែលអ្នកអាចធ្វើបានអំពកការកើតមានីអំពើហិង្សាក្នុងផ្ទះ។ យើងខ្ញុំអាចពន្យល់នូវអ្វីៗដែលអ្នកអាចធ្វើបាន និងបញ្ជូនអ្នកទៅកាន់សេវាយ៉ាងច្រើន។ ឧទាហរណ៍: ទៅកាន់ទីលំនៅគ្រាអាសន្ន ប៉ូលិស និងសេវាពិគ្រោះឱវាទ។ យើងខ្ញុំនឹងរក្សាការសម្ងាត់ក្រៃលែងនូវការទូរស័ព្ទរបស់អ្នក។

## របៀបទាក់ទងសេវារបស់យើងខ្ញុំ

អ្នកអាចទាក់ទងយើងខ្ញុំតាមទូរស័ព្ទ តាមលេខ 8413 6800 ឬតាមរយៈអ៊ីនធើរណិត។

អ្នកទំនាក់ទំនងដំបូងរបស់អ្នកគឺបុគ្គលិកទទួលយក (Intake worker) ។ តួនាទីរបស់បុគ្គលិកទទួលយកគឺដើម្បីពិនិត្យវាយតម្លៃស្ថានការណ៍របស់អ្នក ផ្តល់ឲ្យអ្នកនូវជំរើសទាំងឡាយ និងជួយអ្នកក្នុងការធ្វើផែនការសុវត្ថិភាពមួយ។ យើងខ្ញុំយល់ថា វាអាចមិនងាយស្រួលឡើយក្នុងការប្រាប់នូវកាលៈទេសៈរបស់អ្នកតាមទូរស័ព្ទ ដូច្នេះអ្នកអាចជ្រើសរើសការពិនិត្យវាយតម្លៃដោយជួបផ្ទាល់មុខ។ បុគ្គលិកទទួលយកនឹងខិតខំរៀបចំឲ្យមានការណាត់ជួបអ្នក នៅពេលឆាប់បំផុតទៅតាមលទ្ធភាព។

បើអ្នកត្រូវការជំនួយបន្ថែមដើម្បីសំរេចបាននូវគោលដៅទាំងឡាយ ដែលអ្នកបានគ្រោងធ្វើជាមួយនឹងបុគ្គលិកទទួលយក អ្នកអាចសុំឲ្យបុគ្គលិកជំនួយនិងជួយទ្រទ្រង់ផ្នែកវប្បធម៌ជួយអ្នក។ ឲ្យតែអ្នកបំពេញបានតាមលក្ខណៈវិនិច្ឆ័យរបស់ IWDVS បុគ្គលិកទទួលយកនឹងបញ្ជូនអ្នកទៅកាន់ប្រធានក្រុម ដែលនឹងតែងតាំងបុគ្គលិកជំនួយនិងជួយទ្រទ្រង់ផ្នែកវប្បធម៌ម្នាក់ ដើម្បីធ្វើការជាមួយអ្នក។ នៅពេលដែលយើងខ្ញុំមិនអាចរកបុគ្គលិកដែលមានវប្បធម៌និងភាសាដូចអ្នកបានទេ យើងខ្ញុំនឹងខិតខំរកអ្នកមានវប្បធម៌ដូចគ្នា និងរៀបចំឲ្យមានអ្នកបកប្រែភាសាធ្វើការជាមួយអ្នក។